00197163

ការ/N° C 36/I/III

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 06 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 06 / 2008
ម៉ោង (Time/Heure): 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចបដិសេធសំណើសុំឲ្យដោះលែង
# Ordonnance de refus de mise en liberté
# Order refusing the request for release

យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤

បានឃើញវិធាន ៦៤(២) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើ **ខៀវ សំផន** កើតនៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៣១ ត្រូវបានដាក់ឲ្យនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះ វិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញដីកាឃុំខ្លួនបណ្តោះអាសន្នរបស់យើងចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

00197164

ឯកសារ/ស: C36/III

បានឃើញសំណើសុំឲ្យដោះលែង ដែលបានធ្វើឡើងដោយមេធាវីរបស់ **ខៀវ សំផន** នៅថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៨

បានឃើញសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៨

## I. សេចក្ដីថ្លែងអំពីអង្គហេតុ និងអង្គច្បាប់

### ១) ការស្នើសុំឲ្យដោះលែង ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

នៅក្នុងសម័យជួបសន្ទនាដែលលោកចៅក្រមបានធ្វើ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៨ នៅឯមន្ទីរឃុំឃាំងនៃអ.វ.ត.កទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួន លោក ខៀវ សំផន បានជម្រាបលោកចៅក្រម អំពីសំណូមពររបស់គាត់ចង់បានការអនុញ្ញាត ដើម្បីទៅមើលជំងឺនៅឯផ្ទះគាត់ជុំវិញប្រពន្ធកូន រហូតដល់សុខភាពរបស់គាត់បានជាសះស្បើយឡើងវិញ។ នៅពេលជាសះហើយ គាត់នឹងវិលត្រឡប់មកមន្ទីរឃុំឃាំងវិញ ដើម្បីនឹងបន្តកិច្ចការនីតិវិធី។ គាត់សូមទទួលយល់ព្រមយកគ្រប់លក្ខខណ្ឌទាំងអស់ដែលលោកចៅក្រមដាក់តម្រូវឲ្យ។

គ្រូពេទ្យដែលមើលជំងឺគាត់បានប្រាប់គាត់ថា គាត់នៅមានបញ្ហាតិចតួចទាក់ទិននឹងខួរក្បាល ហើយនិងថាអាការៈរោគគាត់ទាមទារពេលវេលាយូរដើម្បីជាបាន។ រឿងនេះវាអាស្រ័យទៅលើអាការៈផ្លូវចិត្តផងដែរ។ បើគេឲ្យគាត់ត្រឡប់ទៅរស់នៅក្នុងរង្វង់គ្រួសាររបស់គាត់ ដែលគាត់អាចនឹងទទួលបាននូវការថែទាំទាំងថ្ងៃទាំងយប់ ជាពិសេសពីប្រពន្ធរបស់គាត់ អាការៈផ្លូវចិត្តរបស់គាត់នឹងប្រសើរឡើង ហើយនឹងនាំឲ្យមានការប្រសើរឡើងជាទូទៅដល់សុខភាពរបស់គាត់។

អ្វីដែលលោក ខៀវ សំផន សុំលោកចៅក្រមនោះ គឺគ្រាន់តែជាការដោះលែងឲ្យមានសេរីភាពបណ្ដោះអាសន្នប៉ុណ្ណោះ ដើម្បីអាចឲ្យគាត់មើលជំងឺឲ្យបានឆាប់ជា ដើម្បីនឹងត្រឡប់មកបន្តការងារតុលាការបាន។ បើពុំដូច្នោះទេ អាការៈជំងឺរបស់គាត់អាចនឹងកាន់តែដុនដាបទៅៗ រហូតដល់ចំណុច



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ដែលមិនអាចត្រឡប់ក្រោយបាន។ ក្នុងករណីនេះ តើអ្នកណានឹងទទួលខុសត្រូវ ? លោក ខៀវ សំផន បានសុំបន្ថែមទៀត ឲ្យមានគ្រូពេទ្យបង្ហាត់គាត់ ដោយតុលាការជួយចេញសោហ៊ុយផង។

ក្នុងន័យមនុស្សធម៌ និងក្នុងផលប្រយោជន៏តុលាការ ក្រុមមេធាវីការពារក្តីឲ្យលោក ខៀវ សំផន សូមលោកចៅក្រមមេត្តាសម្រេចតាមសំណូមពររបស់លោក ខៀវ សំផន ដោយក្តីអនុគ្រោះ។

**២)** ដោយអនុវត្តតាមវិធានវិធាន ៦៤(២) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ សំណើសុំនេះ អាចទទួលបាន។

## II. សំអាងហេតុនៃសេចក្តីសម្រេច

៣) អាស្រ័យដោយស្ថានភាពសុខភាពរបស់ **ខៀវ សំផន** (ដែលនាំឲ្យគាត់ត្រូវទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ) ត្រូវបានវិនិច្ឆ័យឃើញថាគួរឲ្យព្រួយបារម្ភនោះ កោសលវិច័យវេជ្ជសាស្ត្រមួយ ត្រូវបានសម្រេចឲ្យធ្វើដោយប្រគល់ទៅឲ្យ វេជ្ជបណ្ឌិតជំនាញខាងហទយវិទ្យា (បេះដូង)។ អ្នកជំនាញ ទើបតែដាក់របាយការណ៍របស់ខ្លួន និងឆ្លើយតបទៅនឹងទៅនឹងសំនួរនានា តាមខ្លឹមសារដូចខាងក្រោម៖

*(...) អ្នកជម្ងឺ [ត្រូវបាន] បញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ ម៉ែត្រ ដើម្បីតាមដានការវិវត្តន៍នៃគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាល (accident vasculaire cérébral) ដោយមិនមានការប៉ះពាល់ទៅដល់បេះដូង ដែលអាចពន្យល់បានពីមូលហេតុ និងមិនទាមទារឲ្យមានការព្យាបាលជាពិសេសណាមួយទេ។*

*(...) បញ្ហាដែលសង្កេតឃើញ ទាមទារឲ្យមានការសម្រាកនៅមន្ទីរពេទ្យធ្វើការតាមដានរយៈពេលពីរបីថ្ងៃ ចាប់ពីថ្ងៃទី ២១/០៥/២០០៨ ទៅ ដើម្បីអាចបន្តតាមដានអាការៈខាងក្រៅ និងខាងក្នុងនៃគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាល ដែលបណ្តាលមកពីការស្ទះសរសៃឈាម។*

*(...) នៅពេលភ្លាមៗនេះ វាដូចជាលឿនពេកក្នុងឆ្លើយតបឲ្យបានច្បាស់ថា រយៈពេលនៃការឃុំខ្លួន និងការចូលរួមរបស់គាត់ក្នុងកិច្ចស៊ើបអង្កេត អាចត្រូវបានប៉ះពាល់ដោយសារគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាលនេះ។ វាចាំបាច់ត្រូវមានការតាមដានតាមលក្ខណៈជំនាញជាបន្តទៀត។ យើងខ្ញុំ ផ្តល់ជាយោបល់ថា គួរមានការសម្រាកនៅមន្ទីរពេទ្យធ្វើការតាមដាន*



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

*រយៈពេលមួយសប្តាហ៍។ យើងនឹងអាចពិចារណាពីការវិលត្រឡប់របស់អ្នកជម្ងឺទៅកាន់ទីកន្លែងឃុំឃាំងវិញ នៅពេលណាដែលអាការៈនៃជម្ងឺមានលក្ខណៈធូរស្រាលជាងមុន ។*

*(...) កោសលវិច័យទីពីរ ដែលពាក់ព័ន្ធនឹងជំនាញផ្នែកប្រសាទសាស្ត្រសុទ្ធសាធ ត្រូវតែធ្វើឡើងក្នុងរយៈពេលមួយខែបន្ទាប់ពីគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាលនេះ ដោយប្រើម៉ាស៊ីនស្កែន និង IRM (Imagerie par Résonance Magnétique)ដែលអាចធ្វើបាននៅមន្ទីរពេទ្យ កាល់ ម៉ែត្រ។*

*(...) វាជាការលំបាកក្នុងការកំណត់ពីការវិវត្តន៍នៃគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាល ប៉ុន្តែវាអាចមានការវិវត្តន៍តិចតួច ដោយសារគ្រោះថ្នាក់វាមានលក្ខណៈមិនធ្ងន់ធ្ងរ និង/ឬ មានការវិវត្តន៍មិនអាចត្រួតត្រាបានក្នុងរយៈពេល ២៤ ម៉ោង។ រឿងនេះ អាចធ្វើបានតាមរយៈការវាយតម្លៃមួយខែក្រោយគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាលកាលពីថ្ងៃទី ២១/០៥/២០០៨។ ស្ថានភាពសុខភាពរបស់ជនជាប់ឃុំ ត្រូវបានទទួលរងឥទ្ធិពលជាខ្លាំងដោយហេតុការណ៍គ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាលនេះ។ ចំនុចដែលល្អគឺ គាត់មិនបញ្ហាសុខភាពផ្សេងទៀតទេក្រៅពីនេះ។ វាមិនមានបង្ហាញពីសញ្ញានៃហានិភ័យណាមួយទេ។ គ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាល ទំនងជាមាននៅក្នុងវង្វង់នៃបរិវេណដំបូង មិនមានការរាលដាលបន្ថែមទៀតទេ។ លើសពីនេះទៀត វាមិនមានរោគសញ្ញានៃជម្ងឺបេះដូង ឬសរសៃឈាមដែលនាំឱ្យមានការភ័យខ្លាចថាមានការកើតឡើងនូវគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាលនៅត្រង់បរិវេណផ្សេងទៀតទេ។*

**៤)** នៅក្នុងរបាយការណ៍ដោយឡែកមួយទៀត ដែលបានធ្វើបន្ទាប់ពីការសម្រាកនៅមន្ទីរពេទ្យ ក្រុមវេជ្ជបណ្ឌិតនៃមន្ទីរពេទ្យកាល់ម៉ែត្រ (ដែលជាអ្នកអនុញ្ញាតឱ្យជនជាប់ឃុំវិលត្រឡប់មកមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក វិញ បានធ្វើសេចក្តីសន្និដ្ឋាន ដូចតទៅ៖

**សេចក្តីសន្និដ្ឋាន៖** គឺជាមនុស្សដែលមានអាយុ ៧៧ ឆ្នាំ ទទួលរងគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាលដែលបណ្តាលមកពីការស្ទះសរសៃឈាមកកើតឡើងនៅក្នុងអំឡុងពេលនៃការវិលទៅរកភាពដើមវិញ មានរោគសញ្ញាជម្ងឺក្រពេញទីរ៉ូអ៊ីដ ដែលចាំបាច់ត្រូវមានការតាមដានផ្នែកវេជ្ជសាស្ត្រជាប្រចាំ នៅរៀងរាល់ពីរខែម្តងជាពិសេសទៅលើការពិនិត្យក្រពេញទីរ៉ូអ៊ីដ។

នៅក្នុងរបាយការណ៍នេះ ក្រុមវេជ្ជបណ្ឌិត ផ្តល់ជាអនុសាសន៍ថា ក្រៅពីការព្យាបាលដោយការប្រើថ្នាំត្រូវមានរបបអាហារដែលគ្មានជាតិខ្លាញ់ និងមានជាតិស្ងួដាខ្ពស់ ការប្រើកំលាំងមិនហួសហេតុពេក ការព្យាបាលដោយវិធីធ្វើចលនានិងមានការសម្រាកគ្រប់គ្រាន់។

៥) ដោយផ្អែកទៅលើចំនុចទាំងអស់នេះ វានឹងដូចជាឆាប់ពេកដែលពោលអះអាងថា ស្ថានភាពសុខភាពរបស់ជនត្រូវនៅពេលនេះ មិនអាចឱ្យមានការឃុំខ្លួនបាន។ កោសលវិច័យទីពីរ (ដែលត្រូវប្រគល់ទៅឱ្យវេជ្ជបណ្ឌិតជំនាញផ្នែកប្រសាទសាស្ត្រ) ត្រូវធ្វើជាចាំបាច់ ដូចដែលក្រុមអ្នកជំនាញបានលើកឡើង។ ដូច្នេះ កោសលវិច័យនេះត្រូវបានចាត់តាំងឱ្យធ្វើតាំងពីឥឡូវនេះទៅហើយ។
ក្រោយពេលទទួលបានសេចក្តីសន្និដ្ឋានរបស់វេជ្ជបណ្ឌិតដែលធ្វើកោសលវិច័យ ក្នុងករណីចាំបាច់សហចៅក្រមស៊ើបអង្កេត នឹងចេញសេចក្តីសម្រេចសមស្របមួយទាក់ទិននឹងការឃុំខ្លួន។ នៅពេលនេះការស្នើសុំមានតែត្រូវបានបដិសេធប៉ុណ្ណោះ ហើយសំអាងហេតុនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់យើងចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ នៅរក្សាទុកដដែល។

៦) នៅពេលកំពុងរង់ចាំលទ្ធផលនៃធ្វើកោសលវិច័យទីពីរនេះ ត្រូវបានសម្រេចយល់ព្រមចំពោះការស្នើសុំឱ្យមានការព្យាបាលដោយវិធីធ្វើចលនា ដែលធ្វើឡើងដោយជនជាប់ឃុំ ប្រសិនបើវាត្រូវបានចាត់ទុកថាជាការសមស្របដោយវេជ្ជបណ្ឌិតដែលទទួលបន្ទុកព្យាបាលប្រចាំថ្ងៃជនជាប់ឃុំ។ ដូច្នេះ វេជ្ជបណ្ឌិតរូបនេះ ត្រូវបានស្នើឱ្យចាត់វិធានការចាំបាច់នានា ប្រសិនបើខ្លួនយល់ឃើញថាមានប្រយោជន៍ដើម្បីឱ្យមានការព្យាបាលបែបនេះ។

**ហេតុដូច្នេះ**

សម្រេចបដិសេធសំណើសុំឱ្យដោះលែង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

MARCEL Lemonde    យូ ប៊ុនឡេង

ដីកាសម្រេចនេះតាក់តែងឡើងជាភាសាខ្មែរ និងភាសាបារាំង និងបកប្រែជាភាសាអង់គ្លេសជាក្រោយ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

00197168

C36/III

យើង...........................................បានប្រគល់ដីកានេះដល់ឈ្មោះខាងក្រោមនៅថ្ងៃទី........ខែ.......... ឆ្នាំ...........

**ជនត្រូវចោទ មេធាវីជនត្រូវចោទ សហព្រះរាជអាជ្ញា ការិយាល័យរដ្ឋបាល អ្នកប្រគល់**

តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទ ត្រូវបានប្រាប់ថា:

- ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះ ស្របតាមលក្ខណ្ឌដែលមានចែងក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។
- នៅគ្រប់ករណីទាំងអស់ ជនត្រូវចោទ មានសិទ្ធិត្រូវបាននាំខ្លួនទៅជួបសហចៅក្រមស៊ើបអង្កេត យ៉ាងហោចណាស់រៀងរាល់ ១២០ ថ្ងៃម្តង ហើយ ត្រូវផ្តល់ឱកាសដើម្បីពិភាក្សាអំពីប្រព្រឹត្តិកម្ម និង លក្ខខ័ណ្ឌនៃការឃុំខ្លួន ។
- នៅពេលជួបសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទ អាចធ្វើការស្នើសុំផ្សេងៗ ហើយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីសំណើរនេះ។
- ជនត្រូវចោទ អាចធ្វើការកត់សម្គាល់ មុនពេលដែលសហចៅក្រមស៊ើបអង្កេត សម្រេចអំពីការបន្ត ការឃុំខ្លួនជនត្រូវចោទនេះ។ ជនត្រូវចោទ អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ។
- ក្នុងពេលឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ ឬមេធាវីរបស់គេ អាចធ្វើសំណើសុំដោះលែងទៅសហចៅក្រមស៊ើបអង្កេតបានគ្រប់ពេលវេលា ។
- បើស្ថានភាពផ្លាស់ប្តូរក្រោយពេលដាក់ពាក្យសុំចុងក្រោយ ជនត្រូវចោទ អាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀត ក្នុងរយៈពេលមិនឱ្យតិចជាង ៩០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយលើពាក្យសុំដោះលែងនៅក្រៅឃុំពីពេលមុន។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.